**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

លេខ: ៣៧៦ ប្រ.ក ប.ស្ថ

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់រូបសញ្ញាសម្គាល់ អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវរូបសញ្ញាសម្គាល់អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ នៃប្រកាសនេះ។



អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

**ប្រការ២ .-**

ទម្រង់នៃរូបសញ្ញាសម្គាល់អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ គឺមានរាងខែល ដែលមានសេចក្ដីបរិយាយ និងខ្លឹមសារដូចខាងក្រោម៖

– **ផ្នែកទី១.** ជាស្រទាប់ផ្នែកខាងក្រៅមានផ្ទៃពណ៌បៃតង ព័ទ្ធជុំវិញដោយគំនូសខ្សែពណ៌មាស (លឿង) ដែលមានគំនូសខ្សែខាងក្រៅមានទំហំធំជាងគំនូសខ្សែខាងក្នុង។ នៅផ្ទៃផ្នែកខាងលើចំកណ្ដាលមានរំលេចអក្សរ "**ក្រសួងបរិស្ថាន**" ពណ៌ស និងផ្ទៃផ្នែកខាងក្រោមចំកណ្ដាលមានរំលេចអក្សរ "**អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ**" ពណ៌ស។ នៅផ្ទៃផ្នែកចំហៀងទាំងសងខាង មានរូបសញ្ញាព្រះខ័នពណ៌មាស(លឿង) ដែលតំណាងឱ្យការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត លើកិច្ចការគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិ សម្រាប់មន្ត្រីដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌។

– **ផ្នែកទី២.** ជាស្រទាប់ផ្នែកខាងក្នុងមានរូបជាទេសភាពធម្មជាតិសម្បូរបែប រួមមាន៖

- **ផ្ទៃមេឃខៀវស្រឡះ ភ្នំ ខ្ពង់រាប តំបន់ដីសើម ទឹកសាប និងសមុទ្រ៖** តំណាងឱ្យបរិយាកាសបរិសុទ្ធល្អ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដែលមានមុខងារសំខាន់ៗ រួមមាន៖

  **១.សេវាកម្មផ្គត់ផ្គង់៖** ប្រភពអាហារ ទឹកប្រើប្រាស់ ឈើប្រើប្រាស់ ឱសថ និងថាមពលប្រើប្រាស់ ។ល។

  **២.សេវាកម្មធ្វើនិយ័តកម្ម៖** ធ្វើនិយ័តកម្មធាតុអាកាស ខ្សែសង្វាក់អាហារ និងធ្វើនិយ័តកម្មបន្សុទ្ធទឹក ។ល។

  **៣.សេវាកម្មវប្បធម៌៖** កន្លែងសោភ័ណភាព តំបន់អបិយជំនឿ កន្លែងសិក្សាអប់រំ តំបន់កំសាន្ត និងទេសចរណ៍ ។ល។ និង

  **៤.សេវាកម្មគាំទ្រ៖** ផលិតសារជាតិចិញ្ចឹម បង្កើតដីជាតិដី និងផលិតកម្មបឋម ។ល។

  មុខងារទាំងអស់ខាងលើនេះ មានលក្ខណៈអំណោយផលដល់ មនុស្ស សត្វ និងរុក្ខជាតិ ដែលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ ព្រមទាំងដើរតួនាទីយ៉ាងសំខាន់ក្នុងក្របខ័ណ្ឌតំបន់ និងសកលលោក ក្នុងបរិបទកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការស្តុកឥណទានកាបូន។

- **ដើមឈើធំមួយដើម៖** តំណាងឱ្យរុក្ខជាតិនៅកម្ពុជា ដែលជាប្រភពខ្យល់អុកស៊ីហ្សែនបរិសុទ្ធសម្រាប់ទ្រទ្រង់សុខុមាលភាពមនុស្សនិងសត្វ និងរក្សាបាននូវលំនឹងបរិស្ថានធម្មជាតិ និងជាប្រភពចំណូលរបស់សេដ្ឋកិច្ចជាតិយ៉ាងរឹងមាំពីឥណទានកាបូនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌអនុសញ្ញាអន្តរជាតិ។

- **សត្វស្លាបកំពុងហើរ៖** តំណាងឱ្យភាពសម្បូរបែបនៃប្រភេទសត្វស្លាបនៅកម្ពុជា និងប្រភេទសត្វស្លាបមួយចំនួនដែលមានលក្ខណៈអន្តរជាតិ។

- **សត្វដំរី៖** តំណាងឱ្យសត្វព្រៃគ្រប់ប្រភេទ ដែលមានសារសំខាន់ជាលក្ខណៈជាតិ និងអន្តរជាតិ ហើយក៏បានបង្ហាញនូវភាពរុងរឿងរបស់អរិយធម៌ជាតិខ្មែរតាំងពីសម័យបុរាណ តាមរយៈ